ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១០៤/២៣ គ.ជ.ប.ជ

# របាយការណ៍ខែមេសា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែឧសភា ឆ្នាំ២០២៣

## I. ស្ថានភាពទូទៅ

ក្រសួង ស្ថាប័ន រាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ(ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ-១៩ និងមេរោគបម្លែងថ្មី។

ក្រោយពីពិភពលោកកំពុងតែប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺកូវីដ-១៩ មិនទាន់បានចប់ផង ក៏មានព្រឹត្តិការណ៍ថ្មីមួយទៀត ចាប់ពីខែ កុម្ភៈ ឆ្នាំ២០២២ មកដល់ពេលបច្ចុប្បន្ននេះមានការផ្ទុះសង្គ្រាមរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចទូទាំងសកលលោក ដូចជាប្រេង និងឧស្ម័ន បានឡើងថ្លៃខ្ពស់ រហូតធ្វើឱ្យប្រទេសមួយចំនួនមានសេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង និងមានវិបត្តិជំពាក់បំណុលគេដ៏ធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបាន។

រាជរដ្ឋាភិបាលយើងបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺដ៏ធ្ងន់ធ្ងរថែមទៀត។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍

ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

**១. ការកសាងច្បាប់**

- **ក្រសួងយុត្តិធម៌** បានរៀបចំបន្តពិនិត្យសេចក្តីព្រាងច្បាប់ស្តីពី «អំពើពពោះជំនួស» និងច្បាប់ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស»។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

**២. សន្ធិសញ្ញា**

- **ក្រសួងយុត្តិធម៌**
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
  - បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «បត្យាប័ន» ជាមួយសាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋបេឡារុស និងសាធារណរដ្ឋតួកគី។
- បាន និងកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាស្តីពី «ការផ្ទេរទណ្ឌិត» ជាមួយសាធារណរដ្ឋប៉េរូ សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋតួកគី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ និងព្រះរាជាណាចក្រប៊ែលហ្សិក។

### ខ. ការបង្ការ ទប់ស្កាត់

**១. តាមរយៈការលើកកម្ពស់ការយល់ដឹង**

**១.១. ការអប់រំដោយផ្ទាល់**

១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយសាធារណៈ

នៅក្នុងខែមេសា ឆ្នាំ២០២៣នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **១៣.០៨៧**លើក មានអ្នកចូលរួមសរុបចំនួន **៦១៦.៥៩៦**នាក់ (ធៀបនឹងខែមីនាមានចំនួន **៣៣៩.៧៦៧**នាក់ គឺមានការកើនឡើងចំនួន **២៧៦.៧២៩**នាក់ ស្មើនឹង ៨១,៤៤% ក្នុងនោះស្ត្រីចំនួន ៣០៥.១២៤នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

## តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១២៣ | ១៦.៧៧២ | ៩.៥៣០ | ៥២៧ | ១៥.៣៦៦ | ៦.៧៣២ |
| | សរុប ក្រសួង ស្ថាប័ន | ១.២៣លើក | ១៦.៧៧២នាក់ | ៩.៥៣០នាក់ | ៥២៧លើក | ១៥.៣៦៦នាក់ | ៦.៧៣២នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៤១៣ | ២៧.៤០១ | ១៨.១០៥ | ១.៣៦៥ | ១០៤.៤២៨ | ៥១.៧៨០ |
| ៣ | ខេត្តបាត់ដំបង | ៨៥៤ | ៣៨.៧២០ | ២០.៤០៨ | ៦៩៦ | ២៣.៩៣៨ | ១២.៨១០ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៧៨ | ៨៤.៣៩៨ | ៤៣.៦១១ | ៤៥២ | ៦.១៧៦ | ៣.១៨៤ |
| ៥ | ខេត្តសៀមរាប | ២២៣ | ១៥.៤១៤ | ៩.០០៨ | ៣៦ | ១.៤០៧ | ៨៨០ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៧៩៤ | ២១.១២៦ | ១.០៥៦ | ៤១២ | ១១.៤៨៥ | ៦.០៥៨ |
| ៧ | ខេត្តកំពង់ចាម | ១.៧០១ | ៩០.០៥១ | ៤៥.៥៩៥ | ១ | ៨០ | ៤៥ |
| ៨ | ខេត្តព្រះសីហនុ | ៩៧ | ៥.១៤០ | ៣.៤៣១ | ២ | ១១៨ | ៦៦ |
| ៩ | ខេត្តព្រះវិហារ | ៦ | ២.០១២ | ១.១៩១ | | | |
| ១០ | ខេត្តស្វាយរៀង | ១ | ១២ | ៥ | ៣៤៨ | ១០.៨៧០ | ៤.៤៥៦ |
| ១១ | ខេត្តប៉ៃលិន | ៧៣ | ១.០៨០ | ៣៣៣ | ៣៦ | ១.៣៧៣ | ៣៣៧ |
| ១២ | ខេត្តកោះកុង | ១ | ៧០ | ៥២ | ៨០ | ១.៥៣២ | ៧៥១ |
| ១៣ | ខេត្តកំពត | ១ | ២១២ | ១៥០ | | | |
| ១៤ | ខេត្តកំពង់ធំ | ៣៧០ | ៤៦៩៨៣ | ២៤.២៥៧ | ៣២ | ២១៣១ | ១.០៧២ |
| ១៥ | ខេត្តតាកែវ | ៤០០ | ១៥.៦៣១ | ៨.០៣៥ | ១០៥ | ៣.៧៥៩ | ២.០៩៧ |
| ១៦ | ខេត្តក្រចេះ | ១៤ | ១.០៣៣ | ៥២២ | | | |
| ១៧ | ខេត្តកែប | ៦៥ | ១០.៩៩៣ | ៥.៨០២ | ១៣៨ | ៦.២៨៥ | ៣.៣២៧ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៣៣ | ២.០៤៥ | ៧១ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ១២ | ៨៦៤ | ៦១៩ | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | ៨៤៤ | ១៤.៩៨០ | ៥.០២២ | ៣៦ | ១.៤០៦ | ៧២២ |
| ២២ | ខេត្តត្បូងឃ្មុំ | ២.២៦៥ | ២៩.៦៩៤ | ១៣.៣៤៤ | ៥២ | ១.៤៩៥ | ៦៥៥ |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | ១ | ១៦ | ៥ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៨.៦៤៦លើក | ៤០៧.៨៧៥នាក់ | ២០០.៦២២នាក់ | ៣.៧៩១លើក | ១៧៦.៤៨៣នាក់ | ៨៨.២៤០នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ១៣.០៨៧ លើក | | ចំនួនមនុស្ស ៦១៦.៤៩៦ នាក់ | | ចំនួនស្ត្រី ៣០៥.១២៤ នាក់ | |

## ១.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| អង្គការ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ០៥ | ២២៨ | ១៣២ |
| អង្គការដំណក់ទឹក (ខេត្តបន្ទាយមានជ័យ) | ០៣ | ២២០ | ១៣៣ |
| សរុប | ០៨ លើក | ៨៤៤ នាក់ | ៥៦២ នាក់ |

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន ៦.២៨៦នាក់។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ១៦២លើក។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ៥០លើក។

១.៣. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ឯកឧត្តម ឧត្តមសេនីយ៍ឯក **លី តុងហ៊ុយ** អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ FM 103.5 ក្រោមប្រធានបទវេទិកាស្ត្រី ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស និងលទ្ធផលការបង្ក្រាបអំពើជួញដូរមនុស្សឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣។
- **ខេត្តបាត់ដំបង៖** បានចូលរួមធ្វើជាវាគ្មិន ស្តីពីការអន្តាគមន៍សម្រួលដល់ពលករចំណាកស្រុកដែលចង់វិលមកចូលរួមពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ នៅវិទ្យុជាតិកម្ពុជា FM.92.70MHz។
- **ខេត្តកំពង់ចាម៖** ស្នងការដ្ឋាននគរបាលខេត្តបានចូលរួមជាវាគ្មិន នៅវិទ្យុជាតិនៃមន្ទីរពត៌មានខេត្ត ក្រោមប្រធានបទ៖ការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ។

១.៤. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- **ខេត្តសៀមរាប៖**
  - **រដ្ឋបាលស្រុកអង្គរធំ** បានធ្វើការចែកខិតប័ណ្ណ ដែលមានលេខទូរស័ព្ទសមត្ថកិច្ចសម្រាប់ទំនាក់ទំនងពេលមានហេតុការកើតឡើងជាយថាហេតុ ចំនួន៦៨៥ខិតប័ណ្ណ។
  - **អង្គការមូលនិធិអេ២១** បានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីអំពើជួញដូរមនុស្ស និងចែកសម្ភារព័ត៌មាននានា តាមរយៈខិតប័ណ្ណ ចំនួន ១៣៥ខិតប័ណ្ណ។
- **ខេត្តបន្ទាយមានជ័យ៖** បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃមាន:
  - **អង្គការសាម៉ារីតាន់ភឺស** ចំនួន ៥.៣២០នាក់ (ស្រី២.១៨៦នាក់) កុមារ៤៦៦នាក់ (កុមារី ២៣៤ នាក់)។
  - **អង្គការ** IOM ចំនួន ២.៦៦២នាក់ (ស្រី ១.១៧៤នាក់)។
- **ខេត្តបាត់ដំបង៖ អង្គការសាម៉ារីតាន់ភឺស៖** បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន ៥១៧សន្លឹក ខិត្តប័ណ្ណការទប់ស្កាត់អំពើជួញដូរមនុស្សចំនួន ៥១៧សន្លឹក និងខិត្តប័ណ្ណការបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញចំនួន ៤១៥សន្លឹក។

## ២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ២២២.៨៣០នាក់ (ស្រី៩៩.៧០២នាក់) អនីតិជន ៣.៤៤៦នាក់ (ស្រី ១.២៣២នាក់)៖
  - ស្របច្បាប់ ចំនួន ១៦៨.៦៦៥នាក់ (ស្រី ៧៦.៥៧៩នាក់) អនីតិជន ៤១២នាក់ (ស្រី ១២២នាក់)
  - មិនស្របច្បាប់ចំនួន៥៣.៤៩៤នាក់(ស្រី២២.៨២៧នាក់)អនីតិជន២.០៣០នាក់(ស្រី១.០៨១នាក់)
  - ដាច់ការទាក់ទងចំនួន ៦៧១នាក់(ស្រី ២៩៦នាក់)អនីតិជន ១០៤នាក់(ស្រី ២៩)។

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១២៣.៦៤១នាក់ (ស្រី ៥៨.៣៥០នាក់) អនីតិជន ៤៦៣នាក់ (ស្រី ១៧២នាក់)។
- **ខេត្តបន្ទាយមានជ័យ៖** កងកម្លាំងស្នងការនគរបាលខេត្តឈរជើងតាមបន្ទាត់ព្រំដែន (នគរបាល និងយោធា) បានធ្វើការទប់ស្កាត់ពលករធ្វើចំណាកស្រុកខុសច្បាប់ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានចំនួន ០២លើក មនុស្សចំនួន ១៤នាក់ (ស្រី ០៥នាក់) រួចបានធ្វើកិច្ចសន្យាអប់រំណែនាំកុំឱ្យធ្វើចំណាកស្រុកដោយខុសច្បាប់ទៅក្រៅប្រទេសទៀត។

**២.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ កែប តាកែវ សៀមរាប កំពង់ចាម ព្រះសីហនុ កំពង់ស្ពឺ និងខេត្តបន្ទាយមានជ័យ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ២៤៦គោលដៅ មនុស្សចំនួន ១.៥៦៨នាក់ (ស្រី ១.០៧៥នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង ព្រះវិហារ និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ២៧លើក។

**២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ចំនួន ២០០នាក់ (ស្រី ១៨នាក់) មាន ២១សញ្ជាតិ ក្នុងនោះជនជាតិចិន ៧៤នាក់ កូរ៉េខាងត្បូង ៥៥នាក់(ស្រី០៩នាក់) អាមេរិក ៣៣នាក់(ស្រី ០៤នាក់) កាណាដា ០៨នាក់ ម៉ាឡេស៊ី ០៦នាក់ បារាំង ០៤នាក់ វៀតណាម ០៣នាក់(ស្រី ០១នាក់) អូស្ត្រាលី ០៣នាក់(ស្រី ០២នាក់) ជប៉ុន ០២នាក់ អ៊ីស្រាអែល ០១នាក់ អេស្ប៉ាញ ០១នាក់ ថៃ ០១នាក់ អ៊ីតាលី ០១នាក់ មីយ៉ាន់ម៉ា ០១នាក់ អាឡឺម៉ង់ ០១នាក់(ស្រី) នីហ្សេរីយ៉ា ០១នាក់ អង់គ្លេស ០១នាក់ ឥណ្ឌូនេស៊ី ០១នាក់ បាគីស្ថាន ០១នាក់ អ៊ុយក្រែន ០១នាក់ និងអៀរឡង់ ០១នាក់។ និងវាយតម្លៃបញ្ជូនឱ្យក្រុមការងារច្រកចេញ-ចូលតែមួយចំនួន ១៤៣នាក់ (ស្រី ១៤នាក់) បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ រៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ០៩នាក់ (ស្រី ០៧នាក់)។

**៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ចំនួន ១.១៣៣នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

**១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ០៦ករណី(ធៀបនឹងខែមីនា មានចំនួន ១៩ករណី ថយចុះចំនួន ១៣ករណី) ស្មើនឹង៦៨,៤២% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង បានចំនួន ០៦នាក់(ស្រី ០១នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ១០នាក់ មាន: អាយុក្រោម១៥ឆ្នាំ ០៦នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និង អាយុ១៨ឆ្នាំឡើង ០៣នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៤នាក់ និងគ្រួសារចំនួន ០៦នាក់។ ក្នុងនោះចែកជា៖

- **. ករណីអំពើជួញដូរមនុស្ស (គ្មាន)**
- **. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន ០៦ករណី/១៦ករណី (ថយចុះ ១០ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៦នាក់(ស្រី ០១នាក់)ជនសង្ស័យជាអនីតិជន ០២នាក់។ សង្គ្រោះជនរងគ្រោះ ចំនួន ១០នាក់ មាន: អាយុក្រោម១៥ឆ្នាំ ០៦នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៣នាក់ ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៤នាក់ និងគ្រួសារចំនួន ០៦នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ញាកម្មទាក់នងនឹងពេស្យាចារកុមារ | ០១ | ០៤ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | ០៤ |
| -អំពើអាសប្រាធំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០២ | ០១ |
| *សរុប* | *០៦ ករណី* | *១០ នាក់* | *០៦ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

**១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់**

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស និងក្នុងស្រុកសរុបចំនួន ៤១នាក់(ស្ត្រី) សកម្មភាពមាន ដូចជា៖

**នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ**

- បានទទួលចំនួន ៣៧នាក់ (ស្ត្រី) មកពីប្រទេសចិន ៣៤នាក់ និងប្រទេសម៉ាឡេស៊ី ០៣នាក់ បានសម្ភាសន៍កំណត់អត្តសញ្ញាណបឋម ដើម្បីផ្តល់សេវាសមស្របចំនួន ១៦នាក់ (ករណីអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈ/បង្ខំ ១១នាក់ ជួញដូរកម្លាំងពលកម្ម ០៣នាក់ និងងាយរងគ្រោះ ០២នាក់) មិនទាន់សម្ភាសន៍ ២១នាក់។
- បានទទួលពីនគរបាលមានសមត្ថកិច្ចនៅក្នុងស្រុកចំនួន ០៤នាក់ (ស្ត្រី) ជាករណីអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ។

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់ពីប្រទេសចិន ចំនួន ១៩នាក់(ស្រី)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈទៅចិន ១២នាក់ និងស្នាក់នៅដោយខុសច្បាប់ ០៧នាក់។
  - **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ១៥០លើក មនុស្សចំនួន ១៨.៦១១នាក់ (ស្រី៥.៥៥០នាក់) អនីតិជន ២.១២៧នាក់ (ស្រី ៩៩៣នាក់)។
  - **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០៥លើក មនុស្សចំនួន ៣៦នាក់ (ស្រី ២១នាក់)។
  - **ខេត្តស្វាយរៀង៖** ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរពីសមត្ថកិច្ចវៀតណាម ចំនួន ០១លើក មនុស្សចំនួន ១៩នាក់ (ស្រី ០៤នាក់) អនីតិជន ១៣នាក់ (ស្រី ០៦នាក់)។

### ២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ៥២នាក់ (ស្ត្រី) ជាជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ០៥នាក់ ជួញដូរកម្លាំងពលកម្ម ១៩នាក់ អាពាហ៍ពិពាហ៍ក្លែងក្លាយ ២២នាក់ និងងាយរងគ្រោះ ០៦នាក់។

### ៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ១១នាក់ (ស្ត្រី ) ជាករណីជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ ១០នាក់ និងអាពាហ៍ពិពាហ៍ក្លែងក្លាយ ០១នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ខេត្តបន្ទាយមានជ័យ៖** ស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការសម្ភាសបែបកោសល្យវិច័យ ដល់មន្ត្រីការិយាល័យជំនាញ និងមន្ត្រីនគរបាលស្រុក ក្រុង និងមន្ត្រីសង្គមកិច្ច ឧបត្ថម្ភដោយអង្គការមូលនិធីអេ21 ។ | ០១ | ៣២ | ០៣ |
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន០២ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ០១ | ៤៥ | ១៥ |

| | | | |
|---|---|---|---|
| **ខេត្តព្រះវិហារ៖** មន្ទីរកិច្ចការនារីខេត្ត បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជា ឧបត្ថម្ភដោយអង្គការ UNFPA។ | ០១ | ៣៤ | ១៦ |
| **ខេត្តកំពង់ធំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយអង្គការមូលនិធិហាការ រៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពី "ច្បាប់ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកទៅក្រៅប្រទេស ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការលើកកម្ពស់អក្ខរកម្មហិញ្ញវត្ថុឆ្ពោះទៅ បង្កើនភាពអង់អាចដល់ស្ត្រីពលករទេសន្តរប្រវេសន៍"។ | ០១ | ៣៧ | ២២ |
| សរុប | ០៤ លើក | ១៤៨ នាក់ | ៥៦ នាក់ |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
    - បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយអន្តរក្រសួងពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាពលករដែលកំពុងស្នាក់នៅគ្មានឯកសារ និងកំពុងប្រើប្រាស់ឯកសារធ្វើការងារផុតសុពលភាពក្នុងប្រទេសថៃ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។
    - មានកិច្ចសន្ទនាជាន់ខ្ពស់ ស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងយេនឌ័រនិងបៀតបៀននៅឧស្សាហកម្មកាត់ដេរនៅកម្ពុជា ដែលមានសមាសភាពចូលរួម លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ លោកជំទាវ **សុវណ្ណ វណ្ណារត័** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី លោកស្រី **នៅ សុត្ថា** នាយិកាប្រចាំប្រទេសអង្គការឃែរអន្តរជាតិនៅកម្ពុជា ក្រុមហ៊ុន រោងចក្រឧស្សាហកម្មកាត់ដេរ សហជីព និងអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ សរុបចំនួន **៥៨**នាក់ (ស្ត្រី ៣៨នាក់) នៅសណ្ឋាគារហ៊ីម៉ាវ៉ារី។

### ២. ការទទួលជួបពិភាក្សាការងារ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖** លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបសំណេះសំណាល និងពិភាក្សាការងារជាមួយអង្គការការីតាសស្វីស ពាក់ព័ន្ធនឹងការងារប្រឆាំងការជួញដូរមនុស្ស ជាពិសេសគម្រោងសុវត្ថិភាព ទេសន្តរប្រវេសន៍នៅកម្ពុជា នៅសាលប្រជុំ គ.ជ.ប.ជ។
- **ខេត្តបាត់ដំបង៖** បានទទួលជួបសម្តាសជាមួយអង្គការសាម៉ារីតាន់កឺសសង្គ្រោះអន្តរជាតិ ក្នុងគោលបំណងផ្តល់នូវធាតុចូលសំខាន់ៗក្នុងការធ្វើយុទ្ធសាស្ត្រ៥ឆ្នាំ (២០២៣-២០២៨) ដើម្បីចូលរួមទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងការរំលោកបំពានលើយេនឌ័រ នៅសាលាខេត្តបាត់ដំបង។

### ៣. ការងារទស្សនកិច្ច

- **ខេត្តបន្ទាយមានជ័យ៖** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលទស្សនៈកិច្ច និងសម្តែងការគួរសម្បពីអង្គការកុមារគេតព្រំដែនអន្តរជាតិ ដើម្បីសិក្សាពីកិច្ចសហការផ្តល់សេវាជូនកុមារពីការធ្វើចំណាកស្រុក និងកុមារវិលត្រឡប់ពីប្រទេសថៃ។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៤៣លើក មានអ្នកចូលរួមសរុប **៧៧៦**នាក់ (ស្រី **២៤២**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១០**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **២៤**លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

**V. ទិសដៅខែឧសភា ឆ្នាំ ២០២៣**

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហួតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.................ខែ..........ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..........ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣៤លើក) មនុស្សចំនួន ៧៧៦នាក់ (ស្រី ២៤២នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាដំណើរការ ការអនុវត្តន៍នីតិវិធីប្រតិបត្តិស្តង់ដារ ដើម្បីឆ្លើយតបអំពីអសីលធម៌ក្នុងសង្គមតាមប្រព័ន្ធអនឡាញ នៅទីស្តីការក្រសួងកិច្ចការនារី។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៊ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ៖<br>- បានអញ្ជើញចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីនីតិវិធីនៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស តាមផ្លូវអាកាស ក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាសភាពចូលរួមចំនួន៥០នាក់ តំណាងមកពីអន្តរក្រសួងទាំង ២២ និង០៥អង្គភាព នៅសណ្ឋាគារភ្នំពេញ។<br>- បានអញ្ជើញចូលរួមពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវបន្ទប់ផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនិងយេនឌ័រ ដែលរៀបចំដោយក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី ឧបត្ថម្ភដោយអង្គការUSAID និងអង្គការFhi 360 នៅមន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង។<br>- បានអញ្ជើញចូលរួមប្រជុំពិនិត្យ និងកែសម្រួលសេចក្តីព្រាងផែនការអនុវត្តជាតិ GCM រយៈពេលពីរឆ្នាំ ខែមករា ឆ្នាំ ថ្ងៃទី០១)២០២៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ក្រោមអធិបតីភាព ឯកឧត្តម (ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលប្រជុំក្រសួងការងារ។<br>- បានអញ្ជើញជាអធិបតីសិក្ខាសាលា ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ និងសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០២៣-២០២៥ នៅខេត្តបន្ទាយមានជ័យ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៦ច្បាប់ លិខិតចូល ៣១ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០៧ច្បាប់ លិខិតចូល ១៤ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។<br>- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមេសា ឆ្នាំ២០២៣ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បូកសរុបរបាយការណ៍ប្រចាំខែមេសា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។<br>- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។ |

| | |
|---|---|
| | - ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៧៤ច្បាប់ និងបានចងក្រងជាសៀវភៅជាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។<br>- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន៣១សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក និងលោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមកិច្ចប្រជុំថ្នាក់បច្ចេកទេស ស្តីពីឧបសម្ព័ន្ធនៃនីតិវិធីប្រតិបត្តិបទដ្ឋាន សម្រាប់ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាព ឯកឧត្តម **ឡៅ វ៉េង** អគ្គនាយករង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារប៉ៃតង។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវបន្ទប់ផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនិងយេនឌ័រ ដែលបានរៀបចំឡើងដោយក្រសួងសុខាភិបាល និងក្រសួងកិច្ចការនារី ក្រោមជំនួយឧបត្ថម្ភថវិកាដោយ USAID និង Fhi360 នៅមន្ទីរពេទ្យបង្អែក រាជធានីភ្នំពេញ។<br>- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងក្រុមការងារបច្ចេកទេសព័ត៌មានវិទ្យា ដើម្បីពិភាក្សាលើការងារអភិវឌ្ឍន៍បន្ថែម នូវមុខងារមួយចំនួនរបស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករវិលត្រឡប់ ដើម្បីឱ្យកាន់តែទំនើបទាន់សម័យ និងជួយសម្រួលដល់ការបញ្ចូល ទិន្នន័យបានឆាប់រហ័សជាងមុន នៅសាលប្រជុំ គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- បានចូលរួមកម្មវិធីដាក់ឱ្យដំណើរការ"ការដាក់បញ្ចូលកម្មវិធីបណ្តុះបណ្តាលទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ក្នុងកម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ" ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលរួមសហការ និងឧបត្ថម្ភដោយអង្គការ IOM នៅសណ្ឋាគារភ្នំពេញ។<br>- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយរបស់អង្គការសង្គមស៊ីវិលស្តីពី" អនុសាសន៍វេទិកាអាស៊ានស្តីពីទេសន្តរប្រវេសន៍ការងារ "លើកទី១៥ នៅសណ្ឋាគារសាន់វ៉េ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ២៤លើក អ្នកចូលរួមសរុបចំនួន ៧២៦នាក់ (ស្រី ២៤២នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែមេសា ឆ្នាំ២០២៣ អ្នកចូលរួមចំនួន២៧នាក់ ស្រី១៨នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែមេសា ចំនួន០៩លើក អ្នកចូលរួមចំនួន២៦៣នាក់ ស្រី១៩នាក់។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីស្ត្រី និងភាពជាអ្នកដឹកនាំ នៅសណ្ឋាគារឃើងហ៊ី ក្រុងបាត់ដំបង រៀបចំដោយក្រសួងកិច្ចការនារី។<br>- បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារអន្តរក្រសួងពាក់ព័ន្ធនឹងការងារកិច្ចការពារកុមារខេត្តបាត់ដំបង នៅសាលាខេត្តបាត់ដំបង។ |
| **ខេត្តសៀមរាប** | - បានរៀបចំកិច្ចប្រជុំប្រចាំខែមេសា ចំនួន០៧លើក អ្នកចូលរួមចំនួន២២៩ ស្រី១១៧នាក់។ |
| **ខេត្តកំពង់ស្ពឺ** | - បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើរំលោភបំពានផ្លូវភេទ ការទប់ស្កាត់អំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ ការចំណាកស្រុកខុសច្បាប់ និងកិច្ចការពារជនរងគ្រោះ ចំនួន០៥លើក អ្នកចូលរួមចំនួន២០៧នាក់ ស្រី៨៨នាក់។ |